

## ជំពូកទី១៤

# ការគាំទ្រចំពោះឪពុកម្ដាយ និងអ្នកថែទាំកុមារ

នៅទូទាំងពិភពលោកទាំងមូល ឪពុកម្ដាយ និងសមាជិកគ្រួសារឯទៀតខិតខំធ្វើការយ៉ាងលំបាក ដើម្បីថែរក្សាកូនតូចៗរបស់ពួកគាត់។ នៅពេលគ្រួសារមួយមានកូនដែលមិនអាចស្ដាប់ឮ គឺត្រូវមានបន្ទុកទទួលខុសត្រូវបន្ថែមទៀតដើម្បីធ្វើឱ្យប្រាកដថា កូនទទួលបាននូវអ្វីៗដែលត្រូវការដើម្បីឱ្យគេធំលូតលាស់ល្អ។ ការងារបន្ថែមនឹងធ្វើឱ្យមានភាពខុសប្លែកយ៉ាងប្រពៃចំពោះកុមារ ប៉ុន្តែវាអាចជាភាពតានតឹង និងអស់កម្លាំងយ៉ាងខ្លាំងសំរាប់ឪពុកម្ដាយ។ នៅជំពូកនេះមានព័ត៌មានជួយឪពុកម្ដាយ និងអ្នកថែទាំកុមារថ្លង់ឱ្យចេះរកវិធីលៃលកដោះស្រាយជាមួយស្ថានភាពរបស់ពួកគាត់ និងការថែទាំចំពោះខ្លួនឯងផ្ទាល់ ក៏ដូចជាចំពោះកូនៗរបស់ពួកគាត់។



អ្វីៗទាំងឡាយដែលកើតឡើងចំពោះកូន នឹងប៉ះទង្គិចដល់ពួកយើងយ៉ាងធ្ងន់ធ្ងរ ពីព្រោះពួកយើងរួមសុខទុក្ខក្នុងជីវិតរស់នៅជាមួយកូនៗ។ ក្រុមគ្រួសារដែលមានកូនថ្លង់ជាច្រើនមានអារម្មណ៍តែលតោល ឬក៏ខ្លាចចំពោះអនាគត។ បើឪពុកម្ដាយរួបរួមដើម្បីគាំទ្រគ្នាទៅវិញទៅមក ពួកគាត់អាចធ្វើឱ្យជីវិតកូនថ្លង់របស់ខ្លួនបានរីកចំរើនឡើង។ ពួកគាត់អាចធ្វើការងារជាក្រុម ដើម្បីទាមទារឱ្យសហគមន៍របស់ខ្លួនគាំទ្រកុមារដែលមានបញ្ហាក្នុងការស្ដាប់គ្រប់រូបបានកាន់តែល្អប្រសើរ។

## នៅពេលណាអ្នកដឹងជាលើកដំបូងថា កូនមិនអាចស្ដាប់ឮល្អ

ការដឹងថាកុមារមិនអាចស្ដាប់ឮល្អ ឬក៏ថ្លង់ គឺអាចធ្វើឱ្យអ្នកមិនសប្បាយចិត្តជាខ្លាំង ទោះបីជាករណីនេះកើតឡើងចំពោះក្រុមគ្រួសារដែលមានសាច់ញាតិជាមនុស្សថ្លង់ ឬមិនអាចស្ដាប់ឮក៏ដោយ។ នេះគឺជារឿងធម្មតា។ អ្នកអាចមានអារម្មណ៍ថា :-

- ព្រួយចិត្តអំពីអ្វីដែលត្រូវធ្វើ។




- ខ្លាចអំពីអ្វីទៅហៅថាភាពថ្លង់ និងព្រួយអំពីអនាគត។




- ការបដិសេធ។




- ខឹងនូវអ្វីដែលបានកើតឡើង។




- ភាពឯកោតែម្នាក់ឯង។




- ទោសកំហុសអំពីអ្វីដែលអ្នកបានបង្កឱ្យមានភាពថ្លង់




- ខ្មាសគេដោយសារមានកូនថ្លង់។




- សោកសៅខ្លាំង គ្មានអារម្មណ៍ក្នុងខ្លួនទាល់តែសោះ (ភាពតានតឹងក្នុងចិត្ត)។




- ការទទួលយកតាមព្រហ្មលិខិតកំណត់ ឬក៏ដាក់ទណ្ឌកម្ម។



## យល់ដឹងអំពីការរំជួលចិត្ត




ឪពុកម្តាយ សមាជិកក្នុងក្រុមគ្រួសារឯទៀត និង អ្នកថែទាំកុមារនឹងមានប្រតិកម្មតបទៅការរំជួលចិត្តរបស់ ពួកគាត់ដោយឡែកៗពីគ្នា។ ការប្រសើរបំផុតនោះត្រូវតែឱ្យ បុគ្គលទាំងនោះសំដែងអារម្មណ៍រំជួលចិត្តតាមវិធីរៀងៗខ្លួន ដោយគ្មានការវិនិច្ឆ័យទោស។

ការរំជួលចិត្តដូចជា ព្រួយចិត្ត ឯកោម្នាក់ឯង ឬខ្លាច វានឹងសាបរលាបបន្តិចម្តងៗតាមពេលវេលាដែលកន្លងទៅ។ អ្នកនឹងបានដឹងប្រាកដក្នុងចិត្តថា កុមារមិនអាចស្តាប់ឮ ត្រូវការសេចក្តីស្រឡាញ់ វិន័យ បង្ហាញការថ្នាក់ថ្នម និងការរៀនសូត្រដូចកុមារឯទៀតអញ្ចឹងដែរ។




ការរំជួលចិត្តនឹងវិលត្រឡប់មករកអ្នកវិញ នៅពេលសំខាន់មួយនៃជីវិតរបស់កូនអ្នក ដូចជានៅពេលកូនអ្នកចាប់ផ្តើមទៅសាលារៀន។ ប្រការនេះមិនមានន័យថា មានអ្វីមួយខុសឆ្គងនោះទេ។ វាគ្រាន់តែមានន័យថា អ្នកត្រូវពុះពារឆ្លងកាត់រយៈពេលមួយ ដើម្បីព្រមទទួលយកភាពថ្លង់របស់កូន។

ការរំជួលចិត្តដ៏ខ្លាំងទាំងនេះ អាចជួយឱ្យអ្នកចាប់ផ្តើមធ្វើសកម្មភាពដែលជួយឱ្យជីវិតកូនបានរីកចំរើន។ ឧទាហរណ៍ :- ភាពឯកោអាចជំរុញទឹកចិត្តអ្នក ឱ្យឈានទៅរកមនុស្សថ្លង់ពេញវ័យក្នុងសហគមន៍ ឬក៏ក្រុមគ្រួសារដែលមានកូនថ្លង់ឯទៀត។ ការខឹងសម្បារអាចផ្តល់កម្លាំងឱ្យអ្នកជួយរៀបចំឪពុកម្តាយឯទៀតឱ្យបញ្ចុះបញ្ចូលរដ្ឋាភិបាល ដើម្បីផ្តល់ការអប់រំដល់កុមារថ្លង់។

នៅពេលអ្នកព្រមទទួលស្គាល់ថា កូនរបស់អ្នកគឺជាកុមារមិនអាចស្តាប់ឮ នោះអ្នកនឹងមានចិត្តចាប់ផ្តើមស្រឡាញ់កូន ក្នុងនាមកូនផ្ទាល់ជាបុគ្គលដែលមិនអាចស្តាប់ឮ ហើយកូននឹងផ្តល់ឱ្យអ្នកវិញនូវការគាំទ្រជាច្រើន សេចក្តីស្រឡាញ់ និងរីករាយដូចកុមារគ្រប់រូបអញ្ចឹងដែរ!



## ការគ្រប់គ្រងភាពតានតឹងរបស់អ្នកថែទាំកុមារ




ក្នុងនាមជាឪពុកម្តាយរបស់ក្មេងណាម្នាក់ក៏ដោយ វាគឺជាការងារដ៏លំបាកដូចគ្នា ។ ហើយបើកូនអ្នកមិនអាចស្តាប់ឮល្អ ឬក៏ជាក្មេងថ្លង់ នោះគឺជាការងារកាន់តែលំបាកទៀត ។ ឧទាហរណ៍ ក្រុមគ្រួសារត្រូវតែបង្រៀនកុមារថ្លង់នូវអ្វីៗដែលក្មេងឯទៀតរៀនដោយខ្លួនឯងពីការស្តាប់ឮមនុស្សនិយាយគ្នា ។

វាអាចពិបាកក្នុងការរកពេល និងកម្លាំងពលំចំពោះកិច្ចការបន្ថែមនេះ ។ ទំព័រ182នេះ និងបន្ទាប់មានផ្តល់យោបល់ខ្លះៗពីក្រុមគ្រួសារផ្សេងទៀតអំពីវិធីខុសៗគ្នា ដែលបានជួយពួកគាត់ឱ្យចេះគ្រប់គ្រងភាពតានតឹងនេះ ។

## ការថែរក្សាសំរាប់អ្នកថែទាំ



ឪពុកម្តាយ និងអ្នកថែទាំអាចបីបាច់ថែរក្សាកុមារបានល្អប្រសើរ បើពួកគាត់មានពេលដើម្បីសម្រាកខ្លះៗផងដែរ ។ ប្រការដែលងាយដូចជាទៅផ្សារ ទៅលេងមិត្តភ័ក្តិ ឬសាច់ញាតិ ទៅម៉ាស្សា ឬក៏ជាចំណែកក្នុងក្រុមមួយនៃសហគមន៏ នោះក៏អាចមានប្រយោជន៏ដែរ ។ ត្រូវចាំថាអ្នកអាចជួយកូនបានកាន់តែច្រើន នៅពេលអ្នកមានអារម្មណ៏ធូរស្រាល ។



**សូមចាំថា ត្រូវចេះជួយយកអាសារគ្នាទៅវិញទៅមក ។ ក្នុងនាមជាឪពុកម្តាយ នេះគឺជាកិច្ចការដ៏លំបាកមួយ ។**

ពេលខ្លះ វាមានប្រយោជន៏ចំពោះក្រុមរបស់ឪពុកម្តាយដែលត្រូវជួបជុំសំណេះសំណាលគ្នាអំពីការលំបាកដែលអាចកើតមាន ។ បើសិនជាអ្នកខ្លះមានបញ្ហាលំបាកក្នុងការនិយាយអ្វីមួយនៅក្នុងក្រុម ពួកគាត់ប្រហែលជាអាចប្រឌិតចម្រៀង កំណាព្យ ឬរឿងអំពីស្ថានភាពរបស់ខ្លួន ។ ការគូររូប ឬគំនូរក៏អាចជួយបានដែរ ដើម្បីឱ្យមនុស្សមួយចំនួនសំដែងគំនិត និងអារម្មណ៏របស់គាត់ដោយមិនប្រើការនិយាយ ។ ដើម្បីគូររូប ពួកគាត់មិនចាំបាច់ក្លាយជាអ្នកជំនាញខាងគំនូរនោះទេ ។




សហគមន៍ជាច្រើនមានជំនឿ និងទំនៀមទម្លាប់ដែលជួយដល់ការបន្ធូរអារម្មណ៍ និងសំរាកកាយឱ្យស្ងប់ស្ងៀម ក៏ដូចជាបង្កើនកម្លាំងពលំក្នុងខ្លួន ។ ការអនុវត្តទំនៀមទម្លាប់នេះអាចជួយអ្នកឱ្យថែរក្សាខ្លួនឯងបានល្អប្រសើរ ។

ការបួងសួងសូត្រធម៌



ការសមាធិ



ការហាត់ប្រាណ ឬ សិល្បៈក្បាច់ការពារខ្លួន



## ក្រុមរបស់ឪពុកម្តាយ

**ឪពុកម្តាយមួយក្រុមធ្វើឱ្យជីវិតកុមារី *អ៊ីឡានឌីតា* មានការផ្លាស់ប្តូរយ៉ាងប្រពៃ**

នៅប្រទេសនីការ៉ាហ្គ័រមានស្ត្រីម្នាក់ឈ្មោះ***រ៉ូស្សា*** បានចាប់ផ្តើមសង្ស័យថា មានអ្វីមួយមិនប្រក្រតីចំពោះកូនស្រីគាត់ឈ្មោះ ***អ៊ីឡានឌីតា***។ នៅពេលហៅឈ្មោះ ***អ៊ីឡានឌីតា***មិនបានឆ្លើយតបវិញទេ គឺគ្រាន់តែមានប្រតិកម្មតបទៅនឹងសម្លេងដែលឮខ្លាំងៗតែប៉ុណ្ណោះ ។

ដោយការព្រួយចិត្តចំពោះកូនស្រី ***រ៉ូស្សា***បានយកកូនស្រីទៅជួបវេជ្ជបណ្ឌិត កាលពី***អ៊ីឡានឌីតា***មានអាយុ 16ខែ ។ វេជ្ជបណ្ឌិតបង្ហាញការព្រងើយកន្តើយចំពោះ***រ៉ូស្សា*** ដោយនិយាយថា "កូនរបស់អ្នកមិនអាចស្តាប់ឮអ្វីទាំងអស់ ។ ចាំនាងអាយុប្រាំឆ្នាំសឹមយកមកម្តងទៀត ហើយយើងនឹងពិនិត្យមើលក្រែងលោអាចជួយនាងបានខ្លះ" ។ ***រ៉ូស្សា*** ចាកចេញដោយអារម្មណ៍រន្ធត់ និងវង្វេងជាងមុនពេលដែលគាត់ជួបវេជ្ជបណ្ឌិតទៅទៀត ។



នៅតាមផ្លូវមកផ្ទះវិញ ***រ៉ូស្សា***បានជួបនឹងមិត្តភ័ក្តិម្នាក់ដែលបានប្រាប់គាត់ថា ឱ្យធ្វើការណាត់ជួបនឹងអង្គការក្នុងសហគមន៍ឈ្មោះ**ឡូស់ពីពីតូស** "Los Pipitos" ។ **ឡូស់ពីពីតូស**បានបង្កើតឡើងដោយឪពុកម្តាយមួយក្រុមដែលចង់ឱ្យកូនពិការរបស់ពួកគាត់មានឱកាសអភិវឌ្ឍឱ្យបានដល់កំពូល ។

ថ្វីបើវេជ្ជបណ្ឌិត និងបុគ្គលិកនៅអង្គការ**ឡូស់ពីពីតូស**បានផ្តល់ឱ្យ***រ៉ូស្សា***នូវការវិនិច្ឆ័យរោគដូចគ្នានឹងវេជ្ជបណ្ឌិតមុនថា កូនស្រីរបស់គាត់គឺថ្លង់ទាំងស្រុង ហើយពួកគេក៏បានប្រាប់ឱ្យគាត់មានសង្ឃឹមចំពោះអនាគតផងដែរ ។ ពួកគេបានពន្យល់***រ៉ូស្សា*** ថា ជាមួយការជួយជ្រោមជ្រែងជាពិសេស និងការគាំទ្របន្ថែមពីក្រុមគ្រួសារផ្ទាល់ ***អ៊ីឡានឌីតា***អាចអភិវឌ្ឍបានរីកចំរើនដូចកុមារស្តាប់ឮធម្មតាអញ្ចឹងដែរ ។ ដោយមានការគាំទ្រពីក្រុមឪពុកម្តាយឯទៀតនៅអង្គការ**ឡូស់ពីពីតូស** ***រ៉ូស្សា***ចាប់មានទំនុកចិត្តថា គាត់អាចធ្វើឱ្យជីវិត***អ៊ីឡានឌីតា***មានការប្រែប្រួលរីកចំរើនឡើង ។

ឥឡូវនេះ***រ៉ូស្សា*** គឺជាសមាជិកសកម្មនៅ**ឡូស់ពីពីតូស** ហើយគាត់ធ្វើការដើម្បីផ្តល់ឱ្យឪពុកម្តាយផ្សេងទៀតនូវការគាំទ្រ និងចំណងមិត្តភាពដូចគ្នាដែលគាត់បានរកឃើញកាលពីពេលគាត់ត្រូវការវាអញ្ចឹងដែរ ។

សូមអរគុណដល់ការគាំទ្រពីក្រុមគ្រួសាររបស់គាត់ និងការថែទាំផ្តល់ឱ្យពីអង្គការ**ឡូស់ពីពីតូស** ***អ៊ីឡានឌីតា*** គឺជាក្មេងស្រីដែលមានមនោសញ្ចេតនាជ្រាលជ្រៅ ឈឺឆ្អាល សប្បាយ មានបញ្ញា និងទំនុកចិត្ត។ នាងអាចប្រាស្រ័យទាក់ទង ហើយអាចទៅសាលារៀនធម្មតាបានទៀតផង ។



## ការចាប់ផ្តើមបង្កើតក្រុមមួយ

បើសិនជាអ្នកស្គាល់ឪពុកម្តាយមានកូនថ្លង់ឯទៀតក្នុងសហគមន៍របស់អ្នក ហើយនៅក្នុងតំបន់របស់អ្នកគ្មានក្រុមរបស់ឪពុកម្តាយ វាប្រហែលជាអាចជួយដល់អ្នកដើម្បីផ្តើមឱ្យមានក្រុមរបស់ឪពុកម្តាយ ។ ដោយសារតែគំនិតរបស់បុគ្គលម្នាក់ ក្រុមរបស់ឪពុកម្តាយដ៏រឹងមាំមួយចំនួន និងយ៉ាងសកម្មបានចាប់បង្កើតឡើង ។ តាងនាមឱ្យក្រុមមួយ ឪពុកម្តាយអាចធ្វើរួមគ្នាដើម្បីដោះស្រាយបញ្ហា ។ ការធ្វើកិច្ចការរួមគ្នា ឪពុកម្តាយអាចធ្វើការបានកាន់តែច្រើនជាងពេលពួកគាត់ធ្វើតែម្នាក់ឯង ។




- ចូរស្វែងរកឪពុកម្តាយឱ្យបានពីរនាក់ ឬច្រើនជាងនេះ ឬក៏អ្នកថែទាំដែលចង់បង្កើតជាក្រុម ។ បើសិនជាអ្នកមិនស្គាល់ក្រុមគ្រួសារមានកូនថ្លង់ឯទៀត អ្នកអាចស្វែងរកឪពុកម្តាយដែលមានកូនពិការប្រភេទផ្សេងៗ ។ ឬក៏ភ្នាក់ងារសុខាភិបាលបានស្គាល់ឪពុកម្តាយនៅក្នុងសហគមន៍ជិតខាង ។
- ចូររៀបចំផែនការសំរាប់ប្រជុំនៅពេលណា និងនៅកន្លែងណាមួយ ។ វាអាចជួយផងដែរក្នុងការជ្រើសរើសកន្លែងដែលមនុស្សគ្រប់រូបមានអារម្មណ៍ស្រួលចិត្តក្នុងការពិភាក្សាគ្នា កន្លែងនោះប្រហែលជាបន្ទប់នៃសាលារៀន មណ្ឌលសុខភាព សហករណ៍ ឬក៏កន្លែងគោរពបូជាដូចជា វត្តអារាម ។ នៅការប្រជុំលើកដំបូង ចូរពិភាក្សាអំពីហេតុអ្វីអ្នកធ្វើការប្រជុំ ហើយអ្វីដែលអ្នកសង្ឃឹមថាត្រូវធ្វើ ។
- ប្រហែលជាមនុស្សម្នាក់ ត្រូវតាំងខ្លួនជាអ្នកដឹកនាំនៃការប្រជុំពីរបីលើកដំបូង ។ ប៉ុន្តែជាការសំខាន់មិនត្រូវឱ្យមនុស្សម្នាក់ធ្វើការសំរេចចិត្តសំរាប់ក្រុមទាំងមូលនោះទេ ។ មនុស្សគ្រប់គ្នាក្នុងក្រុមគួរមានឱកាសបញ្ចេញមតិយោបល់ ។ ព្យាយាមរក្សាការពិភាក្សាផ្តោតលើហេតុផលសំរាប់អង្គប្រជុំ ។ បន្ទាប់ពីមានការប្រជុំពីរបីលើកហើយ ចូរផ្លាស់វេនគ្នាដើម្បីដឹកនាំក្រុមរបស់ខ្លួន ។ ប្រការដែលមានមនុស្សខុសៗគ្នាដឹកនាំការប្រជុំនីមួយៗ នឹងជួយឱ្យសមាជិកដែលមិនសូវក្លាហានឱ្យចូលរួមក្នុងក្រុម ។

## ត្រូវចេះជួយគាំទ្រគ្នាទៅវិញទៅមក

ទោះបីជាមនុស្សគ្រប់រូបបានស្គាល់គ្នាច្បាស់លាស់ហើយក៏ដោយ វាអាចទាមទារពេលវេលាសមល្មមដើម្បីឱ្យមនុស្សស្រួលចិត្តហ៊ាននិយាយអំពីអារម្មណ៍ បទពិសោធន៍ និងបញ្ហាដែលពួកគេជួបប្រទះក្នុងការចិញ្ចឹមកូនថ្លង់ ឬកូនមិនអាចស្តាប់ឮ ។ ករណីទាំងនេះទាមទារការអនុវត្ត ។



នេះគឺជាយោបល់ខ្លះៗដើម្បីជួយសមាជិកក្រុមឱ្យមានអារម្មណ៍ស្រួលចិត្ត ហើយទុកចិត្តគ្នាទៅវិញទៅមក :-

**ចូរស្ដាប់អ្នកផ្សេងទៀតនិយាយយ៉ាងប្រុងប្រយ័ត្ន ដោយមិនគិតវិនិច្ឆ័យចំពោះពួកគេ។** សូមរិះគិតអំពីរបៀបដែលអ្នកចង់ឱ្យអ្នកផ្សេងទៀតស្ដាប់អ្នកនិយាយ ហើយព្យាយាមស្ដាប់ពួកគេវិញបែបនោះដែរ ។




**ព្យាយាមកុំបង្គាប់ប្រាប់អ្នកផ្សេងទៀតនូវអ្វីដែលត្រូវធ្វើ ។** អ្នកអាចជួយឱ្យអ្នកផ្សេងទៀតយល់ថា ពួកគេមានអារម្មណ៍បែបណា ហើយចែករំលែកបទពិសោធន៍របស់អ្នក ។ ប៉ុន្តែមនុស្សគ្រប់រូបត្រូវតែធ្វើការសំរេចចិត្តដោយខ្លួនឯង អំពីវិធីដែលប្រសើរបំផុតសំរាប់ចិញ្ចឹមថែទាំកូនរបស់ខ្លួន ។



**សូមគោរពរឿងអាថ៌កំបាំងរបស់គ្នាទៅវិញទៅមក។** ដាច់ខាតកុំប្រាប់អ្នកដទៃទៀតអំពីរឿងអ្វីដែលក្រុមបានពិភាក្សាគ្នា ដរាបណាមនុស្សម្នាក់ៗយល់ព្រមថាវាមិនអីទេ។




## ធ្វើផែនការសំរាប់សកម្មភាព

ឪពុកម្តាយដែលធ្វើការងាររួមគ្នា អាចធ្វើសកម្មភាពដោះស្រាយបញ្ហាបានយ៉ាងច្រើន។ នេះគឺជាជំហានខ្លះៗដែលមានប្រយោជន៍សំរាប់ការធ្វើសកម្មភាព :-

1. ជ្រើសរើសបញ្ហាមួយដែលមនុស្សភាគច្រើនក្នុងក្រុមមានអារម្មណ៍ថាសំខាន់។ ថ្វីបើការផ្លាស់ប្តូរភាគច្រើន ប្រហែលជាត្រូវការក៏ដោយ ក្រុមរបស់អ្នកប្រហែលជាមានប្រសិទ្ធភាពកាន់តែច្រើន បើសិនជាក្រុមអាចធ្វើការលើបញ្ហាមួយក្នុងមួយពេល។ ដំបូងយកបញ្ហាដែលក្រុមរបស់អ្នកមានឱកាសល្អអាចដោះស្រាយបានឆាប់រហ័ស។ បន្ទាប់មកនៅពេលដែលក្រុមរៀនធ្វើការរួមគ្នា អ្នកអាចធ្វើការលើបញ្ហាដែលស្មុគស្មាញជាងមុន។



2. សំរេចចិត្តពីរបៀបដែលអ្នកចង់ដោះស្រាយបញ្ហា ។ ចូរកត់ត្រាវិធីជាច្រើនដែលអាចដោះស្រាយបញ្ហា ហើយរើសយកវិធីមួយដែលប្រើធនធាន និងភាពរឹងមាំរបស់ក្រុមអ្នកបានប្រសើរបំផុត ។




3. ធ្វើផែនការ ។ សមាជិកនៃក្រុមនឹងត្រូវធ្វើអ្វីមួយខុសពីគ្នា ដើម្បីឱ្យហើយការងារនោះ ។ ព្យាយាមកំណត់ថ្ងៃណាដែលការងារនីមួយៗគួរតែបញ្ចប់ ។




4. នៅពេលអ្នកជួបជុំគ្នា ចូរនិយាយអំពីការងារនោះ តើវាដំណើរការដល់ណាហើយ ធ្វើយ៉ាងណាខ្លះហើយ ។ ចូរកែប្រែផែនការរបស់អ្នកតាមត្រូវការ បើសិនជាការលំបាកកើតឡើង ។



## ក្រុមមួយដែលមានធនធានតិចតួច អាចនៅតែធ្វើឱ្យមានភាពខុសគ្នាបានល្អប្រពៃ!

យើងជឿជាក់លើសហគមន៍ទាំងមូល មនុស្សក្នុងភូមិផងរបងជាមួយ ភូមិ ទីក្រុង ឬជាតិទាំងមូល គឺមានការទទួលខុសត្រូវចំពោះការគាំទ្រក្រុមគ្រួសារដែលមានកូនពិការទាំងឡាយ ។ ប៉ុន្តែពេលខ្លះវាទាមទារឱ្យឪពុកម្តាយធ្វើការរួមគ្នា ដើម្បីជំរុញឱ្យសហគមន៍ធំព្រមទទួលយកការទទួលខុសត្រូវនោះ ។ បន្តទៅនេះគឺជារឿងមួយនៅទ្វីបអាហ្វ្រិកភាគខាងត្បូង ឪពុកម្តាយមួយក្រុមដែលបានប្តេជ្ញាចិត្តបង្ហាញថា កាលណាមនុស្សសហការគ្នាហើយដាក់ធនធានរបស់ខ្លួនរួមគ្នា ពួកគាត់អាចជំនះឆ្លងផុតឧបសគ្គ ហើយធ្វើឱ្យមានអ្វីមួយកើតឡើងនៅកន្លែងដែលគ្មានអ្វីៗទាំងអស់!

**កសាងធនធាន - ឥទ្ធិពលនៃការប្តេជ្ញាចិត្ត**

ទីក្រុងមួយក្នុងប្រទេសអាហ្វ្រិកខាងត្បូង កុមារពិការផ្នែកការសិក្សាកម្រឃើញលេងជាមួយកុមារឯទៀត ឬចូលរៀននៅសាលារៀនណាស់ ។ ឪពុកម្តាយភាគច្រើនមិនអាចទៅធ្វើការនៅក្រៅផ្ទះ ពីព្រោះមណ្ឌលគាំពារកុមារពេលថ្ងៃមិនចង់បញ្ចូលកូនៗរបស់ពួកគាត់ក្នុងមណ្ឌល ។ មណ្ឌលនោះប្រាប់ឪពុកម្តាយដែលបានទៅជួបថា "អ្នកឯងមិនអាចប្រាប់ខ្ញុំនូវអ្វីដែលត្រូវធ្វើទេ!"ហើយ"យើងគ្មានគ្រឿងប្រដាប់សំរាប់បង្រៀនកុមារទាំងនេះឡើយ" ។

ឪពុកម្តាយមួយក្រុម ពួកគាត់ជាម្តាយដែលគ្មានមុខរបរ ពួកម្តាយទាំងនោះភាគច្រើនមានចំណេះតិចតួច ឬមិនមានការអប់រំក្នុងប្រព័ន្ធ ពួកគាត់រួបរួមគ្នាហើយសំរេចចិត្តថាត្រូវតែធ្វើអ្វីមួយសំរាប់ក្មេងទាំងនេះ និងក្រុមគ្រួសារផ្ទាល់របស់ខ្លួន ។ ពួកគាត់សំរេចចិត្តថាសមាជិកម្នាក់ ឬពីរនាក់ក្នុងចំណោមពួកគាត់ អាចនៅមើលថែកុមារទាំងអស់ ធ្វើដូច្នេះសមាជិកក្រៅពីនេះនឹងបានទំនេរ ហើយចេញទៅរកការងារធ្វើ ។




ពួកម្តាយទាំងនេះរៀបចំកាលវិភាគសំរាប់មើលថែកូនៗ ។ បុគ្គលម្នាក់ក្នុងចំណោមពួកគាត់បានស្ម័គ្រចិត្តចំអិនម្ហូប ម្នាក់ទៀតធ្វើជាគ្រូបង្រៀន ហើយអ្នកឯទៀតរកការងារណាដែលពួកគាត់អាចធ្វើនៅផ្ទះ ។ ឪពុកម្តាយដែលអាចរកការងារបានធ្វើ ចាប់ផ្តើមបរិច្ចាកបន្តិចបន្តួចដល់អ្នកដែលមើលថែកុមារ និងដល់មណ្ឌលគាំពារកុមារពេលថ្ងៃដែលកំពុងរីកចំរើន ។ ម្តាយម្នាក់ដែលមានការងារធ្វើ ចាប់ផ្តើមទិញសៀវភៅសំរាប់កុមារ ។

ភ្នាក់ងារសង្គមកិច្ចបានឮអំពីក្រុមនេះ ហើយបានមកទស្សនកិច្ចថាតើក្រុមនេះធ្វើអ្វីខ្លះ ។ នាងអាចធ្វើឱ្យរដ្ឋាភិបាលក្នុងស្រុកផ្តល់ថវិកាខ្លះដល់ពួកម្តាយដែលមើលថែកុមារទាំងនោះ ។

ពួកម្តាយមានការប្តេជ្ញាចិត្តខ្ពស់ បានធ្វើការជាមួយធនធានតែប៉ុណ្ណោះ ពួកគាត់អាចបង្កើតមណ្ឌលគាំពារកុមារពេលថ្ងៃសំរាប់កូនៗរបស់ខ្លួន ហើយពួកគាត់អាចប្រកបរបររកប្រាក់ចំណូលបានផងដែរ!

## ធ្វើការរួមគ្នាដើម្បីការផ្លាស់ប្តូរដ៏ល្អប្រពៃ

ក្រុមនៃឪពុកម្តាយធ្វើការលើប្រភេទគម្រោងការជាច្រើន។ ពួកគាត់អាចព្យាយាមដើម្បីធ្វើឱ្យស្ថានភាពសេដ្ឋកិច្ចរបស់គ្រួសារ ឥរិយាបថរបស់សហគមន៍ ឬច្បាប់រដ្ឋាភិបាល និងសេវាកម្មសំរាប់កុមារថ្លង់បានប្រសើរឡើង។ គម្រោងការទាំងអស់ គឺជាផ្លូវមួយដើម្បីជួយកូនរបស់ពួកគាត់។ ដើម្បីឱ្យបានធនធានថែមទៀតសំរាប់កូនៗ ក្រុមនៃឪពុកម្តាយអាច :-

- ស្វែងរកវិធីស្នើសុំមូលនិធិសំរាប់គម្រោងថ្មីមួយ ដើម្បីជួយកុមារថ្លង់។
- ជួយឪពុកម្តាយឱ្យមានជំនាញការងារថ្មី។
- ផ្តល់សិក្ខាសាលាស្តីពីវិធីបង្រៀន និងជួយកូនរបស់ពួកគាត់។
- ចែករំលែកព័ត៌មានអំពីឧបករណ៍ជំនួយការស្តាប់។
- រៀបចំថ្នាក់រៀនភាសាសញ្ញា។
- នាំមនុស្សស្តាប់ឮ និងមនុស្សថ្លង់ឱ្យរួបរួមគ្នា។



**ពួកម្តាយទាំងនេះរៀនរបរកាត់ដេរសំលៀកបំពាក់ ដូច្នេះពួកគាត់អាចរកលុយបានច្រើន ធ្វើការនៅជិតផ្ទះ និងចំណាយពេលបានច្រើនជាមួយកូនរបស់ខ្លួន។**

ក្រុមរបស់ឪពុកម្តាយភាគច្រើនធ្វើការដើម្បីអប់រំសហគមន៍ទាំងមូលអំពីភាពថ្លង់។ ជាញឹកញាប់ពួកគាត់ធ្វើការរួមគ្នាជាមួយមនុស្សថ្លង់។ ក្រុមនេះប្រើសិក្ខាសាលា កម្មវិធីផ្សាយតាមវិទ្យុ ព្រឹត្តិប័ត្រ ផ្ទាំងប្រកាស រោងល្ខោនតាមផ្លូវ ផ្ទាំងរូបភាព (ប៉ុស្ទ័រ) ដើម្បីជួយឱ្យមនុស្សឯទៀតយល់កាន់តែច្បាស់អំពីភាពថ្លង់។

ក្រុមនៃឪពុកម្តាយខ្លះធ្វើការដើម្បីជំរុញឱ្យកម្មវិធីរបស់រដ្ឋ និងច្បាប់សំរាប់កុមារថ្លង់បានល្អប្រសើរឡើង។ ពួកគាត់ទាក់ទងមន្ត្រីនៅក្នុងរដ្ឋាភិបាលដូចជា រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងក្រសួងអប់រំ។ ពួកគាត់ជំរាបទៅរដ្ឋមន្ត្រីអំពីតម្រូវការសេវាកម្មនៅក្នុងសហគមន៍របស់គាត់ ឬក៏តម្រូវការឱ្យមានច្បាប់ការពារកុមារថ្លង់ ឬកុមារមានបញ្ហាក្នុងការស្តាប់។

ពួកគាត់សរសេរលិខិត ចែកចាយពាក្យបណ្តឹង ឬរៀបចំក្បួនកុបកម្ម បើមន្ត្រីរដ្ឋាភិបាលមិនជួយធ្វើឱ្យស្ថានភាពកូនៗរបស់ពួកគាត់បានប្រសើរឡើង។

